# ឥណទានអភិវឌ្ឍន៍ប្រជាជន ( អ៊ី.អេ.ភី ) ម.ក
# ស្ថាប័នមីក្រូហិរញ្ញវត្ថុ

## *របាយការណ៍ប្រចាំឆ្នាំ ២០២០*







អាស័យដ្ឋានៈ ១៨៩អឺ០/ ១៩១អឺ០ មហាវិថីកម្ពុជាក្រោម (ផ្លូវលេខ១២៨) រាជធានីភ្នំពេញ
ទូរស័ព្ទៈ (855) ២៣ ៨៨៤ ៣៥៥ / (៨៥៥) ២៣ ៨៨៤ ៣៦៦
ទូរសារៈ (៨៥៥) ២៣ ៨៨៤ ៣៧៧
អ៊ី-ម៉ែលៈ eapcredit@yahoo.com

# របាយការណ៍ប្រចាំឆ្នាំ ២០២០

**មាតិកា** ទំព័រ


សារលិខិតប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយិកាប្រតិបត្តិ ........ 1

ប្រវត្តិរូបសង្ខេប ........ 2

ការវិវត្តន៍នៃប្រាក់ដើមទុន ........ 3-4-5

ចក្ខុវិស័យ ........ 6

បេសកកម្ម ........ 6

សេវាកម្ម ........ 7-8-9

ធនធានមនុស្ស ........ 10

សេវាសហគមន៍ និងមនុស្សធម៌ ........ 11-12

របាយការណ៍របស់សវនករឯករាជ្យ ........ 13-14-15-16

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 17

របាយការណ៍លទ្ធផលលម្អិត ........ 18

របាយការណ៍បម្រែបម្រួលមូលធន ........ 19-20

របាយការណ៍លំហូរសាច់ប្រាក់ ........ 21

# សារលិខិត

## ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយិកាប្រតិបត្តិ

ជំនួសមុខអោយគ្រឹះស្ថានឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក ខ្ញុំមានបីតិសោមនស្សរីករាយ និងមានកិត្តិយស សំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន ភាគទុនិក និយ័ត្តករ មិត្តភ័ក្ត (អ៊ី.អេ.ភី) ទាំងអស់។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក បានចាប់ផ្តើមធ្វើប្រតិបត្តិការផ្តល់ប្រាក់កម្ចី ចាប់ពីខែមករា ឆ្នាំ២០០៧។ ក្នុងរយៈពេល ១៤ឆ្នាំកន្លងមកនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ី.អេ.ភី បានកសាងសមត្ថភាពបានយ៉ាងរឹងមាំ ដោយប្រើប្រាស់ធនធានរបស់ម្ចាស់ភាគហ៊ុនក្នុងស្រុកទាំងអស់។ យើងមានអតិថិជនដែលមានជំនឿទុកចិត្តមកលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ី.អេ.ភី រួមទាំងបុគ្គលិក ដែលមានជំនាញ ស្មោះត្រង់ និងយល់ច្បាស់ពីតម្រូវការរបស់អតិថិជន។ បច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក បាននិងកំពុងធ្វើសកម្មភាពផ្តល់សេវាឥណទានជូនដល់ អតិថិជនដែលមានមុខរបរ ខ្នាតតូច និងមធ្យមនៅក្នុងខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ចាម រតនគីរី កំពង់សោម ជាយរាជធានីភ្នំពេញ និង រាជធានីភ្នំពេញ លើផ្នែកពាណិជ្ជកម្ម សេវាកម្ម ដឹកជញ្ជូន ជួសជុល សាងសង់ផ្ទះ សិប្បកម្ម និងកសិកម្ម។ល។ ទន្ទឹមនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក បានធ្វើប្រតិបត្តិការស្របតាមគោលការណ៍ របស់ធនាគារជាតិនៃកម្ពុជា ដើម្បីរួមគ្នាបំពេញមុខងារ និងកាតព្វកិច្ចក្លាយជាដៃគូសម្រាប់ធ្វើសមាហរណកម្មអាស៊ាន។

ការរីកចម្រើនគ្រប់វិស័យនៃសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ គឺជាកត្តាលីករបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនបរទេស ក៏ដូចជាពង្រឹងភាពរឹងមាំ និងសុខុមាលភាព មកលើប្រព័ន្ធធនាគារនៅកម្ពុជា។ គិតត្រឹមដំណាច់ឆ្នាំ២០២០ ប្រព័ន្ធធនាគារនៅកម្ពុជា រួមមានធនាគារពាណិជ្ជ ៥២, ធនាគារឯកទេស ១៤, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥, គ្រឹះស្ថានឥណទានជនបទ ២៤៦, ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥, អ្នកដំណើរការតតិយភាគី ៤, គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២៤, ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១, ការិយាល័យតំណាងធនាគារបរទេស ៦, និងអាជីវកម្មប្តូរប្រាក់ ២.៨៨៩។

ការកើនឡើងនូវចំនួនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានឆ្លុះបញ្ចាំងពីសក្តានុពល សេដ្ឋកិច្ចនៅកម្ពុជា ដែលទាក់ទាញវិនិយោគិនបរទេសនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ទោះបីជាមានការប្រកួតប្រជែងយ៉ាងខ្លាំងក្លាពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា ចំនួនអតិថិជនមានការថយចុះបន្តិចបន្តួចក្នុងឆ្នាំ២០១៩ ក៏យើងនៅតែអាចសំរេចផ្លែផ្កាបានល្អបង្គួរ។

ចំពោះផ្នែកប្រតិបត្តិការវិញ យើងបានធ្វើបច្ចុប្បន្នភាពលើគោលការណ៍ប្រតិបត្តិការ និងវិធីសាស្រ្តនៃការប្រតិបត្តិការផ្សេងៗរបស់គ្រឹះស្ថានឱ្យកាន់តែប្រសើរឡើង។ យើងក៏បានខិតខំពង្រឹងធនធានមនុស្សលើវិស័យឥណទានដោយហ្វឹកហ្វឺនមន្ត្រីឱ្យចេះស្ទាត់ និងទទួលបានបទពិសោធន៍ជាច្រើនក្នុងការងាររបស់ខ្លួន។

ជាថ្មីម្តងទៀត តាំងនាមឱ្យក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអតិជន ម្ចាស់ភាគហ៊ុន និយ័តករ និងមិត្តភក្តិទាំងអស់របស់គ្រឹះស្ថានដែលតែងតែបាន សំដែងនូវភក្តីភាព និងផ្តល់ការគាំទ្រដល់យើងខ្ញុំ។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ស្មោះត្រង់ ដល់និយោជិតគ្រប់ជាន់ថ្នាក់របស់គ្រឹះស្ថាន អ៊ី.អេ.ភី ផងដែរ ចំពោះការខិតខំបំពេញភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានភក្តីភាពចំពោះគ្រឹះស្ថាននាពេលកន្លងមក។ ភាពស្មោះត្រង់និងការប្រឹងប្រែងរបស់អ្នកទាំងអស់គ្នាគឺនៅតែជាកត្តា សំខាន់សំរាប់ការរីកចំរើនរបស់គ្រឹះស្ថានយើង។

ភ្នំពេញថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១

ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយិកា

EAP អ៊ី.អេ.ភី

ENTEAN AKPEVATH PRACHEACHUN

ជំទាវបណ្ឌិត តាន់ ផល្លី, Ph.D

# ប្រវត្តិរូបសង្ខេប

- ក្រុមហ៊ុន **ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក** ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ មានដើមទុនចុះបញ្ជីចំនួន ៣,២១៨,៦០០រៀល ស្មើនិង ៧៩៤,០០០ដុល្លាអាមេរិក ចែកជា ៧៧០ភាគហ៊ុន មានម្ចាស់ភាគហ៊ុន ១៦នាក់។

- ដើមទុនក្រុមហ៊ុនត្រូវបានតម្លើងជាបន្តបន្ទាប់ៈ តម្លើងដល់ ២,៥០០,០០០ដុល្លា នៅឆ្នាំ២០០៨ និងដល់ ៣,៧៥០,០០ដុល្លា នៅឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន។

- លក្ខន្តិកៈក្រុមហ៊ុនត្រូវបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ អត្តលេខចុះបញ្ជីចាស់ Co.៩១៩៩KH/២០០៦ និងចុះបញ្ជីក្រោមលេខ ០០០២២៨៦៤ (ថ្មី) ។

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈ្មោះ "**ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក**" បានទទួលអាជ្ញាប័ណ្ណគ្មានកំណត់ (មិនមានពេលបញ្ចប់) ពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ.១៧ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ហើយបានបើកទ្វារដំណើរការ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧ នៅទីស្នាក់ការ ផ្ទះលេខ១៨៩Eo +១៩១Eo មហាវិថីកម្ពុជាក្រោម (ផ្លូវលេខ១២៨) រាជធានីភ្នំពេញ។

- កម្មវត្ថុរបស់ក្រុមហ៊ុនគឺធ្វើហិរញ្ញប្រទានខ្នាតតូច និងមធ្យម ជូនដល់កសិករ សិប្បករ ពាណិជ្ជករ សហគ្រាស តាមជនបទ និងទីផ្សារ ដើម្បីជួយលើកកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដើម្បីរកប្រាក់កំរៃជូនម្ចាស់ភាគហ៊ុនផងដែរ។

-លោកជំទាវឧកញ៉ា តាន់ ផល្លី ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយិកាប្រតិបត្តិ ចាប់ពីដំបូងមក ហើយរក្សាតំណែងទាំងពីរនេះរហូតដល់សព្វថ្ងៃ។



# ការវិវត្តន៍នៃប្រាក់ដើមទុន

ប្រាក់ដើមទុនរបស់ក្រុមហ៊ុនដើមឡើយត្រូវបានចុះបញ្ជីជាប្រាក់រៀល ចំនួន **៣,២១៨,៦០០រៀល** (ស្មើនិង **៧៩៤,០០០ ដុល្លាអាមេរិក**)។ ក្រោយមក ដោយហេតុថា**គ្រឹះស្ថានឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក** បានផ្តល់ប្រាក់កម្ចីទាំងអស់ជាដុល្លានិងដើម្បីជាការងាយស្រួលក្នុងការចុះបញ្ជីគណនេយ្យ ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជា ប្តូរដើមទុនចុះបញ្ជីជាប្រាក់ដុល្លាអាមេរិកវិញ ធនាគារជាតិនៃកម្ពុជាបានយល់ព្រមតាមសំណើរនេះ (យោងតាមលិខិតធនាគារជាតិនៃកម្ពុជាលេខ ធ៧.១៣២.ធត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧)។

បន្ទាប់មកទៀត នៅក្នុងខែកក្កដា ឆ្នាំ២០០៨ ក៏មានការតម្លើងដើមទុនដល់ទៅ **២,៥០០,០០០ដុល្លាអាមេរិក** ដោយមានការ ដោះដូរផ្ទេរភាគហ៊ុនមួយចំនួន និងបន្ថយចំនួនម្ចាស់ភាគហ៊ុន ពី១៦នាក់មកត្រឹម ១២នាក់។ ព្រមជាមួយនោះក៏បានកំណត់ចំនួន សមាជិកក្រុមប្រឹក្សាភិបាលមកត្រឹម៧នាក់។

ក្នុងឆ្នាំ២០១៣ បានតម្លើងដើមទុនម្តងទៀត ស្មើនិង៥០%នៃដើមទុនចុងក្រោយ ឱ្យដល់ **៣,៧៥០,០០០ដុល្លាអាមេរិក** ដោយមានការដោះដូរភាគហ៊ុន បញ្ចូលភាគទុនិកថ្មីម្នាក់ ព្រមទាំងបន្ថយចំនួនសមាជិកក្រុមប្រឹក្សាភិបាលដែលជាភាគទុនិកមកត្រឹម៥នាក់ និងសមាជិកក្រុមប្រឹក្សាអភិបាលឯករាជ្យម្នាក់ត្រូវបានជ្រើសតាំងផងដែរ។



# ក្រុមប្រឹក្សាភិបាល



តាន់ ផល្លី
ប្រធាន



ម៉ុក ប៉ូប៉ុនរិទ្ធ
អនុប្រធាន



ឆាយ ណាយ
សមាជិក



ជឹង សុគន្ធារី
សមាជិក



សុខ ចាន់សូណា
សមាជិក



ប៉ិច សានី
សមាជិកឯករាជ្យ

# គណៈកម្មាធិការ



តាន់ ផល្លី
អគ្គនាយិកា



ម៉ុក ប៉ូប៉ុនរិទ្ធ
គណៈកម្មាធិកាហានិភ័យ



ឆាយ ណាយ
គណៈកម្មាធិការ សវនកម្ម



រតនៈ កក្កដា
សវនករផ្ទៃក្នុង



សូរ សុត្ថា
គណៈកម្មាធិការ ឥណទាន
ប្រធានផ្នែក
ប្រតិបត្តិការ និងហិរញ្ញវត្ថុ



សួស ម៉ន
គណៈកម្មាធិការ ឥណទាន
ប្រធានផ្នែក
ធនធានមនុស្ស និងរដ្ឋបាល

# ចក្ខុវិស័យ

ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាននិរន្តភាព ដែលជួយលើកម្ពស់ជីវភាពរស់នៅ ពង្រឹងពង្រីកសកម្មភាពមុខជំនួញ របស់អតិថិជននៅតំបន់នានា និងជនបទ អោយទទួលបានជោគជ័យ។

# បេសកកម្ម

ផ្តល់កម្ចីតូច និងមធ្យម ជូនដល់អតិថិជន ប្រកបដោយៈ

- សេវាកម្មឆាប់រហ័ស
- យកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជន
- អត្រាការប្រាក់សមរម្យទៅតាមទីផ្សារ ហើយដែលអតិថិជនអាចទទួលយកបាន
- ជៀសវាងកម្ចីហួសប្រមាណដែលនាំឱ្យអតិថិជនមានបំណុលវ័ណ្ឌក





# សេវាកម្ម

**ប្រភេទនិងលក្ខណៈនៃប្រាក់កម្ចី៖**

ការផ្តល់ប្រាក់កម្ចីជាសកម្មភាពតែមួយគត់របស់ស្ថាប័ន អ៊ី.អេ.ភី។ វាមានលក្ខណៈសង្គមផង លក្ខណៈពាណិជ្ជកម្មផង ហើយផ្តល់សំរាប់មុខរបរ ឬកិច្ចការផ្សេងៗ៖

- ការដាំដុះបន្លែ កូនឈើ ផ្កា និងការជួញដូរផលដំណាំទាំងនោះ
- ការចិញ្ចឹមសត្វ
- ទុនអចល័ត/ទុនបង្វិល សំរាប់ជំនួញផ្សេងៗ សិប្បកម្ម ឧស្សាហកម្មខ្នាតតូចនិងមធ្យម
- ទិញឧបករណ៍ដឹកជញ្ជូន និងឧបករណ៍ផលិតកម្មនានា
- សំណង់ខ្នាតតូចនិងមធ្យម
- ជួសជុលកែលំអរលំនៅដ្ឋាន បង្ហើយការសាងសង់ផ្ទះ សង់បន្ទប់អនាម័យ របងផ្ទះ
- ការជួញដូរទូទៅ ខ្នាតមីក្រូ តូច និងមធ្យម

**កំរិតប្រាក់កម្ចី៖** ខ្នាតមីក្រូតូច និងមធ្យម ពី ៣០០ ដល់ ១០០,០០០ដុល្លាអាមេរិក យោងទៅលើសំណូមពររបស់អតិថិជន និងលក្ខណៈសម្បត្តិនៃមុខរបរ/ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន

**រយៈពេល និងរបៀបសងប្រាក់កម្ចី៖**

- រយៈពេលឱ្យខ្ចី ពី៦ខែ ដល់ ៦០ខែបង់ការប្រាក់រាល់ខែ
- សងរំលោះប្រាក់ដើមរាល់ខែ ឬរាល់ត្រីមាស ឬរាល់ឆមាស
- បង់តែការប្រាក់រាល់ខែ ហើយសងផ្តាច់ប្រាក់ដើមនៅចុងគ្រា (Balloon Loan)
- រយៈពេលអនុគ្រោះ (Grace Period)៖ បង់តែការប្រាក់ ក្នុងមួយរយៈពេលណាមួយខាងដើម ហើយសងរំលោះប្រាក់ដើមរាល់ខែក្នុងរយៈពេលបន្ទាប់ និងសងផ្តាច់នៅចុងគ្រា

**ការពារហានិភ័យនិងការខាតបង់៖**

យើងយកចិត្តទុកដាក់ខ្ពស់លើចំណុចដូចខាងក្រោមនេះ

- អតិថិជនត្រូវមានអាជីវកម្មរស់រវើក មានចំណូល និងលំហូរសាច់ប្រាក់គ្រប់គ្រាន់ដែលអាចធានាដល់ការសងបំណុលតាមកាលកំណត់
- ទ្រព្យដាក់បញ្ចាំងធានាបំណុលត្រូវមានឯកសារត្រឹមត្រូវ មានតម្លៃគ្រប់គ្រាន់ និងងាយលក់ដូរ
- សាកសួរព័ត៌មាននៅ "ការិយាល័យព័ត៌មានឥណទាននៃកម្ពុជា" (Credit Bureau Cambodia) មុននិងសំរេចលើកម្ចីនីមួយៗ ដើម្បីបង្ការកម្ចីជាន់គ្នា
- តាមដានឃ្លាំមើលអតិថិជនជាប្រចាំផង




pepsi




# ធនធានមនុស្ស

ប្រតិបត្តិការរបស់គ្រឹះស្ថាន ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក ពឹងផ្អែកលើធនធានមនុស្ស ដែលមានសមត្ថភាព ចរិយាមារយាទល្អ ភាពស្មោះត្រង់ចំពោះស្ថាបន័។ ការអភិវឌ្ឍន៍ធនធានមនុស្សគ្រប់លំដាប់ថ្នាក់ ត្រូវបានប្រព្រឹត្តទៅ តាមវិធីៈ

-ទី១ ផ្ទៃក្នុងស្ថាប័ន មន្ត្រីមានបទពិសោធន៍បង្ហាត់បង្រៀនមន្ត្រីថ្នាក់ក្រោម និងមន្ត្រីចូលថ្មី តាមវគ្គបណ្តុះបណ្តាលខ្លះៗ។ ជាពិសេសក្នុងឱកាសខួប ១០ឆ្នាំ អ៊ី.អេ.ភី បានបំពាក់ផ្នែកទន់ដើម្បីគ្រប់គ្រងឥណទាន និងទិន្នន័យ និងបំពាក់បរិក្ខាអេឡិចត្រូនិច ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងផ្នែករបាយការណ៍ទៅ ធនាគារជាតិនៃកម្ពុជា។ ដូច្នេះមន្ត្រីជំនាញ និងមន្ត្រីឥណទានទាំងអស់ត្រូវបានបណ្តុះបណ្តាល ដើម្បីអនុវត្តន៍អោយបានត្រឹមត្រូវប្រកបដោយប្រសិទ្ធិភាព។ បច្ចុប្បន្ននេះ កម្មវិធីនេះត្រូវបានអនុវត្តជាប្រចាំ និងកែលំអជាបន្តបន្ទាប់សមស្របតាមតំរូវការ។

-ទី២ បញ្ជូនមន្ត្រីប្រតិបត្តិការគ្រប់ជាន់ថ្នាក់ ទៅចូលរួមប្រជុំសន្និសីទ វគ្គបណ្តុះបណ្តាល សិក្ខាសាលាដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ឬសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ឬអង្គការរដ្ឋ អង្គការឯកជននានា។ មន្ត្រីដែលបានចូលរួមក្នុងការប្រជុំទាំងនោះមានភារៈកិច្ចរាយការណ៍ចែករំលែកការយល់ដឹងរបស់ខ្លួនដល់មន្ត្រី ដែលមិនបានទៅចូលរួម ការប្រជុំនោះ។

-ទី៣ រាល់ចុងសប្តាហ៍ មានការប្រជុំរួមបុគ្គលិកទាំងអស់របស់ស្ថាប័ន ធ្វើការដកបទពិសោធន៍លើគ្រប់កិច្ចការក្នុងសប្តាហ៍កន្លងទៅដែលជាឱកាសឱ្យមន្ត្រីប្រតិបត្តិការទាំងឡាយ យកបទពិសោធន៍ទាំងនោះ ធ្វើជាមេរៀនសំរាប់បំពេញកិច្ចការរបស់ខ្លួនឱ្យកាន់តែល្អ និងមានប្រសិទ្ធិភាពថែមទៀត។

-ទី៤ ចូលរួមវគ្គបណ្តុះបណ្តាល regulatory compliance នៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។





# សេវាសហគមន៍ និងមនុស្សធម៌

ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ ជាពិសេសការលើកកម្ពស់ការយល់ដឹងរបស់ស្ត្រី និងកុមារី អ៊ី.អេ.ភី បានសហការយ៉ាងជិតស្និទ្ធជាមួយ

១- សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្នុងគំរោង "ការពារ ទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ ស្ត្រីក្នុងសេវាកំសាន្ត" នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពត ខេត្តកោះកុង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តព្រះវិហារ។ អគ្គនាយិកា **តាន់ ផល្លី** ជាប្រធានគំរោង HAIV/AID ប្រចាំសមាគមនារីកម្ពុជា (CWPD) 2009 – 2013។

២- សមាគមកាយឫទ្ធិនារីកម្ពុជា តាមរយៈវគ្គបណ្តុះបណ្តាល និងសកម្មភាពនានា ដើម្បីអប់រំកុមារី និងយុវតីដោយក្លាយជាពលរដ្ឋល្អរបស់កម្ពុជា។ វគ្គបណ្តុះបណ្តាលរួមមាន អនាម័យខ្លួនប្រាណ សណ្តាប់ធ្នាប់ ការសន្សំសំចៃ ការចេះ ជួយក្រុមគ្រួសារ និងអ្នកដទៃ ការមានវិន័យល្អ និងស្មោះត្រង់ បញ្ឈប់អំពើហិង្សាក្នុងក្រុមគ្រួសារ ការជៀសចេញអោយឆ្ងាយពីគ្រឿងញៀន ការជួញដូរកុមារ និងស្ត្រី ច្បាប់ចរាចរណ៍ អនាម័យទឹកស្អាត បំណិនជីវិត។ល។ (1996 – 2020)

៣- មិត្តតំបន់អាស៊ីប៉ាស៊ីហ្វិច (Friend of Asia Pacific FAWP) ដើម្បីជួយឧបត្ថម្ភ គាំទ្រចលនាកាយឫទ្ធិនារីតំបន់អាស៊ីប៉ាស៊ីហ្វិច និងកម្ពុជា ដែលមានលោកជំទាវ អគ្គនាយិកា **តាន់ ផល្លី** ជាអ្នកសម្របសម្រួលប្រចាំព្រះរាជាណាចក្រកម្ពុជា។ (2018 - បច្ចុប្បន្ន)

៤- Olave Baden Powell Society (OB-PS) ដើម្បីជួយឧបត្ថម្ភ គាំទ្រ ចលនាកាយឫទ្ធិនារីពិភពលោកដែលមានលោកជំទាវ អគ្គនាយិកា **តាន់ ផល្លី** ជាអ្នកសម្របសម្រួលថ្នាក់ជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា។ (2018 - បច្ចុប្បន្ន)

៥- អ្នកសង្កេតការណ៍បោះឆ្នោតទាំង ២៥ ខេត្តរាជធានី។

អ៊ី.អេ.ភី ក៏បានចូលរួមចំណែកជាមួយសកម្មភាពសប្បុរសធម៌របស់អង្គការ កាកបាទក្រហមកម្ពុជា និងអង្គការកុមារកំព្រា ដើម្បីជួយដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនក្រីក្រ និងកុមារជួបការលំបាក។






TAN PHALLY



# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិក
## ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

### មតិសវនកម្មត្រឹមត្រូវមានការលើកលែង

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី 10 ដល់ 58។

ជាមតិរបស់យើងខ្ញុំ ក្រៅពីផលប៉ះពាល់នៃបញ្ហាដូចដែលបានរៀបរាប់នៅក្នុង "មូលដ្ឋានការបញ្ចេញមតិសវនកម្មត្រឹមត្រូវមានការលើកលែង" របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

### មូលដ្ឋានការបញ្ចេញមតិសវនកម្មត្រឹមត្រូវមានការលើកលែង

យើងខ្ញុំពុំបានចូលរួមត្រួតពិនិត្យការរាប់សាច់ប្រាក់នៅក្នុងដៃដែលមានចំនួន2,000,000ដុល្លារអាមេរិក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020នោះទេ។ យើងខ្ញុំមិនអាចកំណត់ថាគួរមាននិយ័តភាពដែលចាំបាច់លើចំនួននៃសាច់ប្រាក់ដែលបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 នោះទេ។

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំគឺឯករាជ្យពីក្រុមហ៊ុន តាមតម្រូវការនៃក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មត្រឹមត្រូវមានការលើកលែងរបស់យើងខ្ញុំ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដោយបានបញ្ចេញមតិត្រឹមត្រូវមានការលើកលែងនៅថ្ងៃទី 27 ខែ មេសា ឆ្នាំ 2020 ដោយសារមូលហេតុដូចតទៅ៖


Diamond Twin Tower (DTT), 5th Floor, Unit 5502, Street Sopheak Mongkul
corner Street Koh Pich, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia
Tel: +855 (96) 555 1455, E-mail: info@fii-associates.com, Website: www.3e-fii.com, www.fii-associates.com

## របាយការណ៍របស់សវនករឯករាជ្យ (ត)

## ជូនចំពោះភាគទុនិក
## ឥណទានអភិវឌ្ឍន៍ប្រជាជន (អុី.អេ.ភី) ម.ក

### បញ្ហាផ្សេងៗ (ត)

1. ក្រុមហ៊ុន មិនបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាម CIFRS for SMEs សម្រាប់របាយការណ៍ហិរញ្ញវត្ថុលើកដំបូងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019 ស្របតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជានោះទេ។

2. ក្រុមហ៊ុន មិនបានអនុវត្តតាមសំវិធានធនអប្បរមា ដែលតម្រូវដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ 2017 ស្តីពីការដាក់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ។

3. ក្រុមហ៊ុន មិនបានកត់ត្រាសំវិធានធនចំនួន 1% លើសមតុល្យនៅធនាគារ (ដោយមិនរាប់បញ្ចូលប្រាក់បញ្ញើជាមួយធនាគារជាតិនៃកម្ពុជា) ស្របតាមតម្រូវការនៃប្រកាសខាងលើស្តីពីការដាក់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ។

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ 2 និង 3 នៃរបាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបានអនុវត្តតាម CIFRS for SMEs នៅថ្ងៃទី1 ខែមករា ឆ្នាំ2019 ដែលមានកាលបរិច្ឆេទអន្តរកាលនៅថ្ងៃទី1 ខែមករា ឆ្នាំ2018។ ស្តង់ដារទាំងនេះ គឺត្រូវអនុវត្តតាមវិធីសាស្ត្រប្រតិសកម្មលើព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ រួមមានរបាយការណ៍ហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ព្រមទាំងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងកំណត់ពន្យល់ពាក់ព័ន្ធផ្សេងៗ។ យើងខ្ញុំ មិនតម្រូវឲ្យធ្វើសវនកម្មលើព័ត៌មានប្រៀបធៀបដែលបានកែប្រែឡើងវិញឡើយ ហើយព័ត៌មានទាំងនេះ មិនត្រូវបានធ្វើសវនកម្មទេ។ ការទទួលខុសត្រូវរបស់យើងខ្ញុំលើព័ត៌មានប្រៀបធៀបទាំងនេះ គឺត្រូវកំណត់ថាតើរបាយការណ៍បានរួមបញ្ចូលនូវព័ត៌មានប្រៀបធៀបដែលតម្រូវដោយ CIFRS for SMEs និងថាតើព័ត៌មានប្រៀបធៀបទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់សមស្រប ឬទេ។

### ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយ ការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ 1 ដល់ទី 5 ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន រំពឹងថានឹងផ្តល់ឲ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការមានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

# របាយការណ៍របស់សវនករឯករាជ្យ (ត)

# ជូនចំពោះភាគទុនិក

# ធនាធានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យផ្សេងទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំគឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវភាពយកចិត្តទុកដាក់ក្នុងអំឡុងពេលសវនកម្ម។

យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

## របាយការណ៍របស់សវនករឯករាជ្យ (ត)

## ជូនចំពោះភាគទុនិក
## ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ចំពោះកត្តាពាក់ពន្ធ័ពីសវនកម្មរួមមានជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្តរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ&អឺសូស៊ីអេត**

**ហេង សិតា**
*នាយកគ្រប់គ្រង*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី20 ខែឧសភា ឆ្នាំ2021

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (អ៊ី.អេ.ធី) ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

| | | 2020 | | 2019 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 2,210,335 | 8,940,805 | 991,049 | 4,038,525 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 6 | 191,732 | 775,556 | 191,220 | 779,222 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ | 7 | 1,221,622 | 4,941,461 | 2,591,712 | 10,561,226 |
| ការវិនិយោគមូលធន | 8 | 10,000 | 40,450 | 10,000 | 40,750 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 922,675 | 3,732,220 | 769,317 | 3,134,967 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 420 | 1,698 | 12,653 | 51,559 |
| ទ្រព្យ និងបរិក្ខារ | 11 | 140,346 | 567,700 | 106,103 | 432,370 |
| ទ្រព្យសកម្មអរូបី | 12 | 4,732 | 19,141 | 9,478 | 38,623 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 13.1 | 6,545 | 26,475 | 17,485 | 71,251 |
| **ទ្រព្យសកម្មសរុប** | | **4,708,407** | **19,045,506** | **4,699,017** | **19,148,493** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | 14 | 27,585 | 111,581 | 6,219 | 25,342 |
| បំណុលពន្ធអប្បបរមា | 13.2 | 23 | 93 | (74) | (302) |
| **បំណុលសរុប** | | 27,608 | 111,674 | 6,145 | 25,040 |
| **មូលធន** | | | | | |
| ដើមទុន | 15 | 3,750,000 | 15,000,000 | 3,750,000 | 15,000,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 16 | - | - | - | - |
| ប្រាក់ចំណេញរក្សាទុក | | 930,799 | 3,736,045 | 942,872 | 3,785,267 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 197,787 | - | 338,186 |
| **មូលធនសរុប** | | 4,680,799 | 18,933,832 | 4,692,872 | 19,123,453 |
| **បំណុល និងមូលធនសរុប** | | **4,708,407** | **19,045,506** | **4,699,017** | **19,148,493** |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ឥណទានអភិវឌ្ឍន៍ប្រជាជន (អុី.អេ.តុី) ម.ក

## របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2020

| | កំណត់សម្គាល់ | 2020 ដុល្លារអាមេរិក | 2020 ពាន់រៀល (កំណត់សម្គាល់2.4) | 2019 ដុល្លារអាមេរិក | 2019 ពាន់រៀល (កំណត់សម្គាល់2.4) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | 18 | 153,305 | 625,024 | 146,077 | 591,904 |
| ចំណាយលើការប្រាក់ | | - | - | - | - |
| **ចំណូលពីការប្រាក់សុទ្ធ** | | 153,305 | 625,024 | 146,077 | 591,904 |
| ចំណូលកម្រៃ និងជើងសារ | | 15,534 | 63,332 | 7,949 | 32,209 |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 19 | 12,756 | 52,006 | 12,912 | 52,319 |
| **ចំណូលប្រតិបត្តិការសរុប** | | 181,595 | 740,362 | 166,938 | 676,432 |
| ចំណាយលើប្រាក់បៀវត្សរ៍ | 20 | (152,662) | (622,403) | (152,047) | (616,094) |
| រំលស់ | | (23,846) | (97,220) | (22,743) | (92,155) |
| ចំណាយទូទៅ និងរដ្ឋបាល | 21 | (95,001) | (387,319) | (81,240) | (329,184) |
| ចំណាយពន្ធអប្បបរមា | | (1,891) | (7,710) | (1,670) | (6,767) |
| **ប្រាក់ខាតលើប្រតិបត្តិការ** | | (91,805) | (374,290) | (90,762) | (367,768) |
| (តំហយ)/ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | 9 | 90,672 | 369,670 | (2,351) | (9,526) |
| **ប្រាក់ខាតមុនដកពន្ធ** | | (1,133) | (4,620) | (93,113) | (377,294) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 14.3 | (10,940) | (44,602) | (783) | (3,173) |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (12,073) | (49,222) | (93,896) | (380,467) |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (140,399) | - | 270,686 |
| **ប្រាក់ខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | (12,073) | (189,621) | (93,896) | (109,781) |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2019 | 3,750,000 | 15,000,000 | 1,036,768 | 4,165,734 | - | 67,500 | 4,786,768 | 19,233,234 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (93,896) | (380,467) | - | - | (93,896) | (380,467) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 270,686 | - | 270,686 |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | (93,896) | (380,467) | - | 270,686 | (93,896) | (109,781) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **3,750,000** | **15,000,000** | **942,872** | **3,785,267** | **-** | **338,186** | **4,692,872** | **19,123,453** |

## ធនាគារអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 3,750,000 | 15,000,000 | 942,872 | 3,785,267 | - | 338,186 | 4,692,872 | 19,123,453 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (12,073) | (49,222) | - | - | (12,073) | (49,222) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (140,399) | - | (140,399) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | (12,073) | (49,222) | - | (140,399) | (12,073) | (189,621) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **3,750,000** | **15,000,000** | **930,799** | **3,736,045** | **-** | **197,787** | **4,680,799** | **18,933,832** |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# ឥណទានអភិវឌ្ឍន៍ប្រជាជន (អ៊ី.អេ.ភី) ម.ក

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020

| | 2020 | | 2019 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់2.4) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (12,073) | (49,222) | (93,896) | (380,467) |
| *និយ័តភាពលើ៖* | | | | |
| ចំណាយពន្ធអប្បបរមា | 1,891 | 7,709 | 1,670 | 6,767 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 10,940 | 44,602 | 783 | 3,173 |
| (តំហយ)/ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | (90,672) | (369,670) | 2,351 | 9,526 |
| រំលស់ | 23,846 | 97,220 | 22,743 | 92,155 |
| ខាតពីការលក់ទ្រព្យ និងបរិក្ខារ | 1,648 | 6,720 | - | - |
| | (64,420) | (262,641) | (66,349) | (268,846) |
| *បម្រែបម្រួល៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (62,686) | (255,571) | 368,696 | 1,493,956 |
| ទ្រព្យសកម្មផ្សេងៗ | 12,233 | 49,874 | (2,273) | (9,210) |
| បំណុលផ្សេងៗ | 21,366 | 87,109 | 539 | 2,184 |
| សាច់ប្រាក់(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពប្រតិបត្តិការ | (93,507) | (381,229) | 300,613 | 1,218,084 |
| ពន្ធអប្បរមាដែលបានបង់ | (1,794) | (7,314) | (1,834) | (7,431) |
| សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពប្រតិបត្តិការ | (95,301) | (388,543) | 298,779 | 1,210,653 |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (82,491) | (336,316) | (1,410) | (5,713) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | 27,500 | 112,118 | - | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (54,991) | (224,198) | (1,410) | (5,713) |
| ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | (150,292) | (612,741) | 297,369 | 1,204,940 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី1 ខែមករា | 3,586,406 | 14,614,605 | 3,289,037 | 13,215,351 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (102,783) | - | 194,314 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 31 ខែ ធ្នូ (កំណត់សម្គាល់22) | 3,436,114 | 13,899,081 | 3,586,406 | 14,614,605 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។